# យុទ្ធសាស្ត្ររេដបូកជាតិ

## សេចក្តីព្រាងលើកទី ២

### ជំពូកទី១ ដល់ ទី៩

កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ
ក្រុងព្រះសីហនុ ថ្ងៃទី២០-២១ ខែឧសភា ឆ្នាំ២០១៥

# ជំពូក ១៖ សេចក្តីផ្តើម

## ១.១. រេដបូកនៅថ្នាក់អន្តរជាតិ

UNFCCC រដ្ឋភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍ ត្រូវបានលើកទឹកចិត្តឱ្យរួម ចំណែកអនុវត្តវិធានការកាត់បន្ថយក្នុងវិស័យ ព្រៃឈើ តាមរយៈការអនុវត្តសកម្មភាពខាងក្រោម ទៅតាមអ្វីដែលភាគីនីមួយៗចាត់ទុកថាសមស្រប និងទៅតាមសមត្ថភាព និងកាលៈទេសៈក្នុងប្រទេសនីមួយៗ៖

ក. កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ

ខ. កាត់បន្ថយការបំភាយឧស្ម័នពីការរិចរឹលព្រៃឈើ

គ. ការអភិរក្សស្តុកកាបូនព្រៃឈើ

ឃ. ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព

ង. ការបង្កើនស្តុកកាបូនព្រៃឈើ

ប្រភព: UNFCCC Conference of the Parties, Decision 1/CP. Par.70

## ១.២. ការវិវឌ្ឍនៃរេដបូកនៅកម្ពុជា

- COP ក្នុងប្រទេសឥណ្ឌូនេស៊ី នៅឆ្នាំ ២០០៧ មានការ ប្រកាសថា *"រាជរដ្ឋាភិបាលកម្ពុជា គាំទ្រយ៉ាងខ្លាំងក្លាដល់ការដាក់បញ្ចូលការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ (GHG) ពីការអេភិរក្សព្រៃឈើ និងការបញ្ចៀសមិនឲ្យមានការបាត់បង់ព្រៃឈើ ក្រោយកិច្ចព្រមព្រៀងក្យូតូ បញ្ចប់"*
- កម្ពុជាបានរៀបផែនទីបង្ហាញផ្លូវក្នុងការអនុវត្តរេដបូក
- ប្រទេសកម្ពុជាទទួលមូលនិធិពី UN-REDD និងFCPF របស់ធនាគារពិភពលោក ដើម្បីអនុវត្តនូវផែនទីបង្ហាញផ្លូវរេដបូក

## ១.៣ សេចក្ដីសម្រេច របស់ UNFCC ស្ដីពីយុទ្ធសាស្ត្រ ឬផែនការសកម្មភាពជាតិស្ដីពីរេដបូក

UNFCCC បានដាក់ចេញនូវដំណើរការ វិធាននិងទម្រង់ការ សម្រាប់ឱ្យប្រទេសកំពុងអភិវឌ្ឍ ទទួលបានការទូទាត់ផ្អែកតាមលទ្ធផល (RBP) សម្រាប់សកម្មភាពរេដបូករបស់ពួកគេ។ ក្របខ័ណ្ឌ Warsaw សម្រាប់រេដបូក រំឮកថា ដើម្បីឱ្យរដ្ឋភាគីជាប្រទេសកំពុងអភិវឌ្ឍ អនុវត្តសកម្មភាពដែលបានលើកឡើងនៅក្នុងកិច្ចព្រមព្រៀង Cancun ក្នុងគោលបំណងឈានទៅទទួលបានការទូទាត់ផ្អែកតាមលទ្ធផល គួរមានការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ ឱ្យបានពេញលេញ (MRV) លើសកម្មភាពទាំងនេះ ៖

ក. យុទ្ធសាស្ត្រ ឬផែនការសកម្មភាពជាតិ

ខ. កម្រិតយោងនៃការបំភាយឧស្ម័នពីព្រៃឈើ និង/ឬកម្រិតយោងព្រៃឈើនៅថ្នាក់ជាតិ

គ. ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ

ឃ. ប្រព័ន្ធសម្រាប់ផ្ដល់ព័ត៌មានអំពីរបៀបដែលការធានាសុវត្ថិភាព Cancun ទទួលបា

ង. ការយកចិត្តទុកដាក់ និងគោរពតាម ក្នុងកំឡុងពេលទាំងមូលនៃការអនុវត្តសកម្មភាពរេដបូក

# ១.៣ សេចក្តីសម្រេច របស់ UNFCC ស្តីពីយុទ្ធសាស្ត្រ ឬផែនការសកម្មភាពជាតិស្តីពីរេដបូក



# ជំពូក ២ ៖ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងដីព្រៃនៅកម្ពុជា

- ប្រទេសកម្ពុជាមានផ្ទៃក្រឡា ១៨១០៣៥ គីឡូម៉ែត្រការ៉េ
- ព្រៃឈើប្រមាណជា ១០, ៧ លានហិចតា លើ ៥៧% នៃផ្ទៃដីសរុប
- ជាប្រទេសដែលមានព្រៃឈើច្រើនជាងគេមួយ នៅអាស៊ីអាគ្នេយ៍នេះ
- ប្រទេសកម្ពុជាផ្តល់ និយមន័យព្រៃឈើ ដោយប្រើប្រាស់ប៉ារ៉ាម៉ែត្រមួយចំនួន ដូចជា៖ *គម្របព្រៃដែលត្រូវមានដើមឈើយ៉ាងហោចណាស់ ១០ ភាគរយ ក្រឡាផ្ទៃអប្បបរមា ០,៥ ហិចតា និងកំពស់ដើមឈើអប្បបរមា ៥ ម៉ែត្រ។*

# ២.១. កត្តាដែលនាំឱ្យមានការបាត់បង់ព្រៃឈើ និងការរិចរឹលព្រៃឈើនៅកម្ពុជា

**តារាងទី ១ ៖ ការបែងចែកចំណាត់ថ្នាក់ព្រៃឈើឡើងវិញ ដើម្បីសម្រេចឱ្យបាននូវគម្រប ព្រៃឱ្យបាន ៦០ ភាគរយ**

| | ក្រសួងបរិស្ថាន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | |
|---|---|---|---|---|---|
| ចំណុចដៅដៅ | តំបន់ការពារ ប្រមាណជា ២,៨ លានហិចតា (២០០ ០០០ ហិចតា សម្រាប់ការប្រើប្រាស់ ផ្សេងទៀត និងទុកមិន ប្រើប្រាស់) | ព្រៃការពារ ប្រមាណជា ៣ លានហិចតា | សហគមន៍ ព្រៃឈើ ប្រមាណជា ២ លានហិចតា | ព្រៃសម្បទាន ត្រូវបាន បែងចែកចំណាត់ថ្នាក់ ជាព្រៃការពារ និង ព្រៃផលិតកម្មវិញ សម្រាប់ផ្ទៃដី ០,៣ លានហិចតា | ព្រៃផលិតកម្ម ប្រមាណជា ២,៥ លានហិចតា (១០០០០០ ហិចតា សម្រាប់ការប្រើ ប្រាស់ផ្សេងទៀត និងទុកមិនប្រើប្រាស់) |

## ២.១. កត្តាដែលនាំឱ្យមានការបាត់បង់ព្រៃឈើ និងការរិចរឹលព្រៃឈើនៅកម្ពុជា (បន្ត)

- ប្រទេសកម្ពុជា ត្រូវបានចាត់ចំណាត់ថ្នាក់ជាប្រទេស ដែលមាន "***គំរបព្រៃកម្រិតខ្ពស់ ការបាត់បង់ ព្រៃឈើខ្ពស់***" ដែលមានព្រៃឈើប្រមាណ ១០,៧ លានហិចតា នៅក្នុងឆ្នាំ ២០០៦ និងអត្រានៃការបាត់បង់ព្រៃឈើប្រចាំឆ្នាំ ០,៨ ភាគរយ ចន្លោះពីឆ្នាំ ២០០២ ដល់ ២០០៦

*(មានព្រៃឈើប្រមាណជា ៣៧៩ ៤៨៥ ហិចតា បានបាត់បង់ នៅក្នុងរយៈពេលនេះ)*

- កំណើនសម្ពាធនៃការអភិវឌ្ឍ ជាពិសេស ***តម្រូវការដីធ្លីសម្រាប់សម្បទានដីសង្គមកិច្ច និង សេដ្ឋកិច្ច*** បានបង្កឱ្យមានការកើនឡើងយ៉ាងឆាប់រហ័សនូវអត្រាបាត់បង់ព្រៃឈើ ចាប់តាំងពីឆ្នាំ ២០០៤-៥ មក ដែលបង្ហាញថាអត្រាគោល (baseline) នៃការបាត់បង់ព្រៃឈើរបស់ប្រទេសកម្ពុជា នាពេលបច្ចុប្បន្ននេះ ប្រហែលជាច្រើនជាង ០,៨ ភាគរយ

## ២.១. កត្តាដែលនាំឱ្យមានការបាត់បង់ព្រៃឈើ និងការរិចរឹលព្រៃឈើនៅកម្ពុជា (បន្ត)

- ភាពងាយស្រួលជាងមុនក្នុងការចេញចូលទៅកាន់តំបន់ព្រៃដាច់ស្រយាល ដែលពីដំបូងកើតឡើង ដោយសារតែការកើនឡើងយ៉ាងឆាប់រហ័សនៃសកម្មភាពកាប់ឈើជាលក្ខណៈពាណិជ្ជកម្ម នៅក្នុងទសវត្សរ៍ ១៩៩០ ដែលនាំឱ្យរដ្ឋាភិបាលប្រកាសឱសានវាទលើការកាប់ឈើ នៅក្នុងឆ្នាំ ២០០២ និង ដោយសារគម្រោងកសាងផ្លូវ កាលពីពេលថ្មីៗនេះ។

- ភាពមិនប្រាកដប្រជានៃការកាន់កាប់ដីធ្លី ដែលលើកទឹកចិត្តឱ្យមានការដណ្តើមដីធ្លីពីសំណាក់អ្នកកាន់កាប់មិនរៀបរយ សូម្បីតែនេះត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់ ក្រោមច្បាប់ភូមិបាលឆ្នាំ ២០០១ ក៏ដោយ។

- កង្វះសមត្ថភាពរបស់អាជ្ញាធរ នៅតាមតំបន់ដាច់ស្រយាល ក្នុងការគ្រប់គ្រងព្រៃឈើឱ្យបានគ្រប់ ជ្រុងជ្រោយ ទៅតាមច្បាប់ព្រៃឈើ ឆ្នាំ ២០០២ ច្បាប់ស្តីពីតំបន់ការពារ ឆ្នាំ ២០០៨ និងច្បាប់ភូមិបាល ឆ្នាំ ២០០១ ដែលចាត់ទុកព្រៃឈើថាជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

## ២.១. កត្តាដែលនាំឱ្យមានការបាត់បង់ព្រៃឈើ និងការរិចរឹលព្រៃឈើនៅកម្ពុជា (បន្ត)

- ការកើនឡើងយ៉ាងឆាប់រហ័សនូវការពង្រីកតំបន់កសិកម្ម និងសកម្មភាពអភិវឌ្ឍន៍ក្នុងទ្រង់ទ្រាយធំដទៃទៀត ដែលនាំឱ្យការរានព្រៃយកដីនៅតាមតំបន់មួយចំនួនកាន់តែរាលដាលធំឡើងៗ។ ជាធម្មតា សកម្មភាពទាំងនេះ កើតឡើងដោយសារមានការប្រកាសថាតំបន់នេះ តំបន់នោះនឹងត្រូវក្លាយជាតំបន់សម្បទានដី សង្គមកិច្ច និងសេដ្ឋកិច្ច ជាដើម។

- ការកើនឡើងនូវតម្រូវការវត្ថុធាតុដើម នៅថ្នាក់តំបន់ និងសកលលោក។ និង

- ភាពក្រីក្រតាមតំបន់ជនបទ ដែលនៅតែមានច្រើននៅឡើយ នៅក្នុងប្រទេសកម្ពុជា។

## ២.២. យុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា

ការរៀបចំយុទ្ធសាស្ត្ររេដបូករបស់ប្រទេសកម្ពុជា ធ្វើឡើងដោយមានការពិចារណាលើ *បទពិសោធន៍* ដែលមានកន្លងមក និងលើយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ ដែលមានស្រាប់ ពោល *គឺមិនមែនជាការផ្តួចផ្តើមគោលនយោបាយ រចនាសម្ព័ន្ធច្បាប់ ឬការរៀបចំអភិបាលកិច្ចថ្មីឡើយ*

## ២.២. យុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា

- ការគ្រប់គ្រងតំបន់ការពារ ផ្អែកតាមច្បាប់ស្តីពីតំបន់ការពារ ឆ្នាំ២០០៨ ច្បាប់ស្តីពីការការពារ បរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ឆ្នាំ១៩៩៦ ព្រះរាជក្រឹត្យស្តីពីការបង្កើត និងការកំណត់តំបន់បម្រុងធម្មជាតិ ឆ្នាំ១៩៩៣ និងបទពិសោធន៍ពីគម្រោងកន្លងមក (ដូចជា តំបន់ការពារសំកុស លំផាត់ ប្ញកគោ វីរៈជ័យ គូលេនព្រហ្មទេព ។ល។)

- ការគ្រប់គ្រងព្រៃការពារ ផ្អែកតាមច្បាប់ព្រៃឈើឆ្នាំ២០០២ និងអនុក្រឹត្យស្តីពីតំបន់ព្រៃការពារ និងបទពិសោធន៍ពីគម្រោងកន្លងមក (ឧ. មណ្ឌលគីរី តំបន់ភ្នំក្រវ៉ាញ) រួមនឹងការសាកល្បងសកម្មភាពរេដបូក នៅតំបន់ព្រៃការពារសីមា។

- សហគមន៍ព្រៃឈើ - ការអភិវឌ្ឍសហគមន៍ព្រៃឈើ បានទទួលការគាំទ្រពីផែនការយុទ្ធសាស្ត្រជាតិស្តីពីសហគមន៍ព្រៃឈើ ឆ្នាំ២០០០ គោលនយោបាយព្រៃឈើជាតិឆ្នាំ២០០២ ប្បញ្ញត្តិនៅក្នុងច្បាប់ព្រៃឈើឆ្នាំ២០០២ ដែលផ្តល់លទ្ធភាពឱ្យមានការបង្កើតសហគមន៍ព្រៃឈើនៅតំបន់ព្រៃផលិតកម្ម អនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើឆ្នាំ២០០៣ គោលការណ៍ណែនាំស្តីពីសហគមន៍ព្រៃឈើឆ្នាំ ២០០៦ និងបទពិសោធន៍ជាមួយនឹងសហគមន៍ព្រៃឈើជាច្រើនដែលកំពុងមាន រួមនឹងការសាកល្បងរេដបូក នៅក្នុងសហគមន៍ព្រៃឈើនៅឧត្តរមានជ័យ។

## ២.២. យុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជា

- សហគមន៍នៃសាទ ដែលមានការគាំទ្រពីព្រះរាជក្រឹត្យស្តីពីសហគមន៍នៃសាទ ឆ្នាំ ២០០៤ អនុក្រឹត្យស្តីពីសហគមន៍នៃសាទ ឆ្នាំ២០០៥  និងច្បាប់ជលផល ឆ្នាំ២០០៦។
- សហគមន៍តំបន់ការពារ ផ្អែកតាមសេចក្តីព្រាងប្រកាសស្តីពីសហគមន៍តំបន់ការពារ បច្ចុប្បន្ននេះ តំបន់ការពារភាគច្រើនមានសហគមន៍តំបន់ការពារមួយ ឬច្រើន។
- ការគ្រប់គ្រងឡូតិ៍នៃសាទ។
- តំបន់ការពារ និងអភិរក្សធនធានជលផល។
- ការចេញប័ណ្ណកម្មសិទ្ធិដីធ្លីដល់ជនជាតិដើមភាគតិច (អនុក្រឹត្យលេខ៨៣ ឆ្នាំ២០០៩ ស្តីពីការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច)។

## ២.៣. យុទ្ធសាស្ត្រគ្រប់គ្រងដែលមានស្រាប់ ដើម្បីដោះស្រាយបញ្ហាដែលនាំឱ្យមានការបាត់បង់ ព្រៃឈើ និងការរិចរឹលព្រៃឈើ នៅកម្ពុជា

១. កម្មវិធីព្រៃឈើជាតិ (NFP) -រយៈពេលវែង ២០ ឆ្នាំ (២០១០-២០២៩)

២. ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងតំបន់ការពារ (NPASMP) សម្រាប់តំបន់ការពារដែលមានផ្ទៃដី ៣លាន  ហិចតា បង្កើតឡើងទៅតាមច្បាប់ស្តីពីតំបន់ការពារឆ្នាំ ២០០៨ ផែនការយុទ្ធសាស្ត្រជាតិគ្រប់គ្រងតំបន់ការពារ  (សេចក្តីព្រាងបឋមសម្រាប់ពិភាក្សា)

៣. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រស្តីពីវិស័យជលផល (SPFF) ពិពណ៌នាលំអិតអំពីផែនការគ្រប់គ្រងរយៈពេលវែង ២០ ឆ្នាំ (២០១០-២០២៩) និងផែនការសកម្មភាពអភិវឌ្ឍវិស័យជលផលរយៈពេល ៣ ឆ្នាំ ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រវិស័យជលផល ២០១០

# ជំពូកទី ៣ ៖ យុទ្ធសាស្រ្តជាតិរេដបូករបស់ប្រទេសកម្ពុជា

## ៣.១. គោលបំណង

យុទ្ធសាស្រ្តជាតិរេដបូករបស់ប្រទេសកម្ពុជា ត្រូវបានរៀបចំឡើង សម្រាប់គោលបំណងដូចតទៅ ៖

1. ដើម្បីផ្តល់នូវមូលដ្ឋាន និងដាក់ចេញនូវទិសដៅ សម្រាប់ប្រព័ន្ធអភិបាលកិច្ច និងប្បញ្ញត្តិកម្មរួមគ្នា សំដៅជានាឱ្យមានការអនុវត្តគោលនយោបាយ និងវិធានការនានា ដែលបានកំណត់នៅក្នុងជំពូកទី ៤ ប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌

2. ដើម្បីបំពេញលក្ខខណ្ឌ ដែលប្រទេសកម្ពុជាត្រូវបំពេញតាម ក្រោមUNFCCC ដើម្បីអាចទទួលបានការទូទាត់ផ្អែកតាមលទ្ធផល សម្រាប់គោលនយោបាយ និងវិធានការដែលបានអនុវត្ត

3 ដើម្បីរៀបចំនូវដំណើរការ និងអភិក្រមរួម ដែលមានលក្ខណៈជាប្រព័ន្ធ សម្រាប់គ្រប់គ្រងព្រៃឈើ ការពារជីវចម្រុះ និងរួមចំណែកកាត់បន្ថយភាពក្រីក្រ ប្រកបដោយនិរន្តរភាព

## ៣.២. គោលដៅ

គោលដៅខាងក្រោម ត្រូវបានរៀបចំឡើង ផ្អែកទៅតាមសកម្មភាព ដែលត្រូវបានកំណត់ និងអនុវត្ត ដូចដែលមាននៅក្នុងផែនទីបង្ហាញផ្លូវរេដបូករបស់ប្រទេសកម្ពុជា (២០១១)។

**គោលដៅរយៈពេលខ្លី (ត្រឹមចុងឆ្នាំ ២០១៥) ៖ ដំណាក់កាលត្រៀមខ្លួន - សកម្មភាពរួមមាន ៖**

1. ការគ្រប់គ្រងដំណើរការត្រៀមខ្លួនសម្រាប់រេដបូកនៅថ្នាក់ជាតិ ការជម្រុញឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធ និងផែនការបង្កើនការយល់ដឹង ប្រកបដោយប្រសិទ្ធភាព ស្របតាម គោលការណ៍ ដែលត្រូវបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវរេដបូកថ្នាក់ជាតិ
2. ការបង្កើតយន្តការសម្របសម្រួលនៅថ្នាក់ជាតិ ដូចជា ក្រុមការងារ លេខាធិការដ្ឋានរបស់ក្រុមការងារ ក្រុមបច្ចេកទេស ក្រុមពិគ្រោះយោបល់ និងក្រុមយេនឌ័រ ដើម្បីធានាឱ្យមានការអនុវត្តគោលនយោបាយ និងវិធានការរេដបូកប្រកបដោយ ប្រសិទ្ធភាព ប្រសិទ្ធផល និងសមធម៌
3. ការរៀបចំយុទ្ធសាស្ត្រជាតិរេដបូកកម្ពុជា និងក្របខ័ណ្ឌអនុវត្ត រួមនឹងអភិក្រមថ្នាក់ជាតិ ដែលស្នើឡើងសម្រាប់ធានាសុវត្ថិភាព/ប្រព័ន្ធធានាសុវត្ថិភាព និងការចែករំលែកគ្រឿងលើកទឹកចិត្តនានា
4. សំណើស្តីពីការបង្កើតប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ (NFMS) សម្រាប់ការវាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់ (MRV)
5. សំណើស្តីពីការកំណត់កម្រិតយោងការបំភាយឧស្ម័នពីព្រៃឈើ/កម្រិតយោងព្រៃឈើ
6. ការរៀបចំគំរូសម្រាប់អនុវត្ត ផ្អែកទៅតាមលទ្ធផល ការសាកល្បងការចែករំលែក អត្ថប្រយោជន៍ និងការធានាសុវត្ថិភាព។ សង្ខេប វាយតម្លៃ និងចងក្រងមេរៀន និង បទពិសោធន៍នានា។

## ៣.២. គោលដៅ

**គោលដៅរយៈពេលមធ្យម (២០១៦-២០២០) ៖ ដំណាក់កាលអនុវត្ត - សកម្មភាពរួមមាន ៖**

1. ការរៀបចំ និងអនុវត្តសាកល្បង NFMS, SIS, និង FREL/FRL ដំបូង
2. ត្រៀមរៀបចំសម្រាប់ការអនុវត្តគោលនយោបាយ និងវិធានការរេដបូកពេញលេញ ដោយប្រើប្រាស់អភិក្រម ផ្អែកតាមលទ្ធផលនៅថ្នាក់ជាតិ
   1. កំណែទម្រង់សិទ្ធិកាន់កាប់ដីធ្លី និងអភិបាលកិច្ចដីធ្លី
   2. ការពង្រឹងការអនុវត្តច្បាប់ព្រៃឈើ
   3. កសិកម្មប្រកបដោយនិរន្តរភាព
   4. ពង្រឹងគោលនយោបាយជាតិស្តីពីការគ្រប់គ្រងព្រៃឈើដែលមានស្រាប់ ជាពិសេស
      1. កម្មវិធីព្រៃឈើជាតិ
      2. ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងតំបន់ការពារ
      3. ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល
3. រួមចំណែកចំពោះគោលនយោបាយអភិវឌ្ឍន៍នៅថ្នាក់ជាតិ ជាពិសេស
   1. យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដំណាក់កាលទី ៣
   2. ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨
   3. ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា ២០១៤-២០២៣
   4. គោលនយោបាយជាតិស្តីពីការអភិវឌ្ឍបៃតង ឆ្នាំ ២០១៣

## ៣.២. គោលដៅ

**គោលដៅរយៈពេលវែង (ចាប់ផ្តើមពីឆ្នាំ ២០២១ ទៅ)៖ ដំណាក់កាលអនុវត្តសកម្មភាព ផ្អែកតាមលទ្ធផល សកម្មភាព រួមមាន៖**

1. FREL/FRL, SIS, និង NFMS ត្រូវបានកំណត់ និងបង្កើតឡើង និងដាក់ឲ្យអនុវត្ត ហើយអ្វីដែលសំខាន់ជាងគេនោះ គឺគេអាចធ្វើការវាយតម្លៃបច្ចេកទេសលើកម្រិតយោង និងប្រព័ន្ធទាំងនេះបាន

2. ការអនុវត្តគោលនយោបាយ និងវិធានការរេដបូកពេញលេញ នៅថ្នាក់ជាតិ

3. ការទូទាត់ត្រូវបានធ្វើឡើង ទៅតាម ការកាត់បន្ថយនូវការបំភាយឧស្ម័ន ឬការកើនឡើងការស្រូបកាបូន ដែលបានផ្ទៀងផ្ទាត់ ដោយវាស់វែងធៀបជាមួយនឹង FREL/FRL ដែលមានការវាយតម្លៃបច្ចេកទេសត្រឹមត្រូវ

4. ព្រៃឈើនិងផ្ទៃដី របស់ប្រទេសកម្ពុជា នៅតែស្រូបកាបូនដោយសារតែការអនុវត្តយុទ្ធសាស្ត្រជាតិរេដបូក ក៏ដូចជាគោលនយោបាយ និងវិធានការពាក់ព័ន្ធនានា សំដៅធានានិរន្តរភាពនៃមុខងារខាងសេដ្ឋកិច្ច និងខាងសេវាប្រព័ន្ធបរិស្ថានរបស់ព្រៃឈើ

## ៣.៣. គោលការណ៍ណែនាំ

**ការរៀបចំយុទ្ធសាស្ត្រជាតិរេដបូកកម្ពុជាគួរ ៖**

1. កសាងសមត្ថភាពក្នុងប្រទេសរបស់ស្ថាប័នរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធមិនមែនរដ្ឋាភិបាល
2. ឈរលើមូលដ្ឋានតួនាទីភារកិច្ចដែលមានស្រាប់  និងគាំទ្រដល់យន្តការសម្របសម្រួលដែលមាន ស្រាប់
3. គាំទ្រដល់ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រគ្រប់គ្រងធនធានព្រៃឈើ ដែលមានស្រាប់
4. មានបរិយាប័ន្ន (inclusive) និងតុល្យភាព ទាំងរវាងស្ថាប័នរដ្ឋាភិបាលផង និងតួអង្គពាក់ព័ន្ធមិនមែនរដ្ឋាភិបាលផង
5. ប្រើប្រាស់មេរៀន  ដែលទទួលបានពីដំណើរការរៀបចំគោលនយោបាយមុនៗ
6. ខិតខំផ្តល់នូវធនធានហិរញ្ញវត្ថុ ឲ្យបានច្រើន ដោយអាចព្យាករដឹងមុនបាន  សម្រាប់អនុវត្ត និងពង្រីកវិសាលភាពយុទ្ធសាស្ត្រ
7. គ្រប់គ្រងព្រៃឈើ ដែលកំពុងមាន
8. កសាងការយល់ដឹង ដល់តួអង្គពាក់ព័ន្ធនានា
9. មានសង្គតិភាព  ជាមួយនឹងដំណើរការចរចាអន្តរជាតិ ក្រោមក្របខ័ណ្ឌ UNFCCC និង
10. ដាក់បញ្ចូលមេរៀនដែលទទួលបានពីគម្រោងបង្ហាញពីរេដបូក ដែលមានស្រាប់ ប្រសិនបើអាចធ្វើ បាន

## ៣.៤. ដំណើរការរៀបចំយុទ្ធសាស្ត្រ

| សេចក្តីព្រាង | អ្នកពាក់ព័ន្ធ | កាលបរិច្ឆេទ កំណត់ |
|---|---|---|
| គ្រោងឆ្អឹង | TF, TT, CG, GG, និង ET * | ៣០ សីហា ២០១៤ |
| បឋម | | ៥ មករា ២០១៥ |
| ទីពីរ | | ១០ មេសា ២០១៥ |
| ទីបី | | ១ មិថុនា ២០១៥ |
| ទីបួន | TF, TT, CG, GG, និង ET<br>កិច្ចពិគ្រោះ យោបល់យ៉ាងទូលំទូលាយនៅថ្នាក់ជាតិនិងថ្នាក់ ក្រោមជាតិ | ១០ កក្កដា ២០១៥ |
| ចុងក្រោយ | TF, TT, CG, GG, និង ET | ១៥ សីហា ២០១៥ |

ការអនុម័តលើសេចក្តីព្រាងចុងក្រោយ ដោយក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងត្រូវសម្របសម្រួលដោយមន្ត្រីបង្គោលរេដបូកនៅថ្នាក់ជាតិ

# ជំពូកទី ៤ ៖ ការអនុវត្តយុទ្ធសាស្រ្តជាតិស្តីពីរេដបូក

## ៤.១. ដំណាក់កាលត្រៀមខ្លួន ត្រឹមចុងឆ្នាំ ២០១៥ - ប្រទេសកម្ពុជាបានត្រៀមខ្លួនរួចរាល់

- ប្រទេសកម្ពុជាបានសម្រេចបាននូវវឌ្ឍនភាពគួរឱ្យកត់សម្គាល់ជាច្រើន នៅក្នុងដំណាក់កាលត្រៀមខ្លួនសម្រាប់រេដបូក។

- វឌ្ឍនភាពមួយចំនួន រួមមាន ការរៀបចំឯកសារបច្ចេកទេស និងការសិក្សា ដែលផ្តល់នូវមូលដ្ឋាន សម្រាប់ឲ្យប្រទេសកម្ពុជារៀបចំសមាសភាគចំនួន ៤ ដែលត្រូវបានកំណត់ក្របខ័ណ្ឌ Warsaw ស្តីពីរេដបូក ដូចជា យុទ្ធសាស្រ្តជាតិ, SIS, NFMS និង FREL/FRL ជាដើម

- ជារួម សមាសភាគទាំង ៤ នៃក្របខ័ណ្ឌ Warsaw សម្រាប់រេដបូក កំពុងស្ថិតនៅក្រោមដំណាក់កាលផ្សេងៗនៃការអភិវឌ្ឍកន្លងមក។ គេរំពឹងថា ត្រឹមចុងឆ្នាំ ២០១៥ ប្រទេសកម្ពុជានឹងមានការរៀបចំ NFMS, FREL/FRL, និង SIS ដំបូង។

## ៤.២. ដំណាក់កាលអនុវត្ត ចាប់ពីឆ្នាំ ២០១៦ ដល់ ឆ្នាំ ២០២០

- ដូចដែលបានលើកឡើង នៅក្នុងជំពូកទី ២ កត្តាដែលនាំឱ្យមានការបាត់បង់ព្រៃឈើ និងការរិចរឹលព្រៃឈើ នៅកម្ពុជា កើតឡើងទាំងក្នុង ទាំងក្រៅវិស័យព្រៃឈើ។ ដូច្នេះ សកម្មភាព ដែលត្រូវអនុវត្ត ជា ផ្នែកមួយនៃយុទ្ធសាស្ត្រជាតិស្តីពីរេដបូកនេះ ក៏ត្រូវផ្តោតលើកត្តាទាំងនេះផងដែរ។
- នៅក្នុងវិស័យព្រៃឈើ កត្តាដែលបានរកឃើញទាំងនេះ អាចដោះស្រាយបានមួយភាគធំតាមរយៈយុទ្ធសាស្ត្រគ្រប់គ្រងព្រៃឈើ ដែលមានស្រាប់ ដែលយុទ្ធសាស្ត្រទាំងនេះសុទ្ធតែមានដាក់បញ្ចូលកំណែទម្រង់កម្មសិទ្ធិដីធ្លី និងការគ្រប់គ្រងរួមគ្នានៅថ្នាក់មូលដ្ឋាន។
- ប៉ុន្តែ ការអនុវត្តយុទ្ធសាស្ត្រទាំងនេះ ជួបប្រទះនឹងឧបសគ្គ ដោយសារកង្វះធនធានហិរញ្ញវត្ថុ ដែលអាចបំពេញឱ្យបាន ដោយរេដបូក។

## ៤.៣. ដំណាក់កាលសកម្មភាពផ្អែកទៅតាមលទ្ធផលជាក់ស្តែង ចាប់ពីឆ្នាំ ២០២១ ទៅ

- គោលបំណងចម្បង សម្រាប់ដំណាក់កាលនេះ គឺប្រទេសកម្ពុជា ត្រូវមាន NFMS, FREL/FRL និង SIS សម្រាប់អនុវត្ត ដែលមានសមត្ថភាពកត់ត្រាការបំភាយឧស្ម័ន ដែលត្រូវបានកាត់បន្ថយ តាមរយៈការអនុវត្តសកម្មភាព ដែលកំណត់នៅក្នុងដំណាក់កាលទីពីរ ពីឆ្នាំ ២០១៦ ដល់ ២០២០ ហើយក្នុងពេលជាមួយគ្នា ធានាឲ្យមានការផ្តោតការយកចិត្តទុកដាក់ និងគោរពដល់ការធានាសុវត្ថិភាព ដែលបានកំណត់នៅទីក្រុង Cancun។

សូមអានទំព័រ48 សម្រាប់ព័ត៌មានបន្ថែម

FOREST CARBON PARTNERSHIP FACILITY

UNDP

Empowered lives.
Resilient nations.

# យុទ្ធសាស្ត្ររេដបូកជាតិ

## សេចក្តីព្រាងលើកទី ២

## ជំពូកទី៥ ដល់ ៩

កិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីយុទ្ធសាស្ត្ររេដបូកជាតិ

ក្រុងព្រះសីហនុ ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៥

# ជំពូកទី ៥ ៖ ក្របខ័ណ្ឌ និងប្រព័ន្ធធានាសុវត្ថិភាពរេដបូក

- ដើម្បីទទួលបានហិរញ្ញប្បទានទៅតាមលទ្ធផលដែលសម្រេចបាន រដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍ គួរមានប្រព័ន្ធមួយ សម្រាប់ផ្តល់ព័ត៌មានសង្ខេបចុងក្រោយគេបំផុត អំពីរបៀបដែលការការពារសុវត្ថិភាពរេដបូកទាំងអស់បានទទួល***ការយកចិត្តទុកដាក់ និងគោរពតាម***

- ចាប់ពីខែ មិថុនា ដល់ខែ សីហា ឆ្នាំ ២០១៤ កិច្ចពិគ្រោះយោបល់ថ្នាក់ក្រោមជាតិចំនួន ៤ ត្រូវបាន រៀបចំឡើង ដើម្បីប្រមូលយោបល់របស់អ្នកពាក់ព័ន្ធនានាអំពីហានិភ័យខាងសង្គម និងបរិស្ថាន ពាក់ព័ន្ធនឹង រេដបូក ដែលអាចកើតមានឡើង។ កិច្ចប្រជុំទាំងនេះមានអ្នក***ចូលរួម ២៤៩ នាក់*** មកពីរាជធានីខេត្ត***ចំនួន ២៤*** លើខេត្តរាជធានី***ចំនួន ២៥ នៅក្នុងប្រទេសកម្ពុជា។***

- នៅក្នុង***ខែ ធ្នូ ឆ្នាំ ២០១៤*** កិច្ចពិគ្រោះយោបល់ថ្នាក់ជាតិមួយ ត្រូវបានរៀបចំឡើង ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសរុបចំនួន ៦៨ នាក់ ដើម្បីប្រមូលយោបល់របស់ពួកគេលើគោលការណ៍ និងលក្ខណៈវិនិច្ឆ័យ ដែលត្រូវបានស្នើឡើងទាំងនេះ។

# កិច្ចព្រមព្រៀង Cancun (សេចក្តីសម្រេចចិត្ត១/ CP.១៦)

**ពេលដែលដំណើរការសកម្មភាពបានយោងទៅក្នុងកថាខ័ណ្ឌ៧០ ការធានាសុវត្ថិភាពដូចខាងក្រោមនេះគួរតែត្រូវបានលើកកម្ពស់៖**

ក. បំពេញបន្ថែម ឬស្របទៅនឹង គោលបំណងកម្មវិធីព្រៃឈើជាតិ និងអនុសញ្ញាអន្តរជាតិ

ខ. រចនាសម្ព័ន្ធអភិបាលកិច្ចមានតម្លាភាព និងមានប្រសិទ្ធិភាពដែលគិតពីច្បាប់ និងអធិបតេយ្យភាពជាតិ

គ. គោរពចំពោះចំណេះដឹង និងសិទ្ធិរបស់ជនជាតិដើមភាគតិច និងសមាជិកសហគមន៍មូលដ្ឋាន

ឃ. ការចូលរួមពេញលេញនិងមានប្រសិទ្ធិភាពរបស់ស្ថាប័នពាក់ព័ន្ធជាពិសេសជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋាន

ង. ស្របជាមួយនឹងការអភិរក្សព្រៃធម្មជាតិ និងភាពសម្បូរបែបជីវសាស្រ្ត

ច. សកម្មភាពដើម្បីដោះស្រាយហានិភ័យនៃការត្រឡប់ថយក្រោយ

ឆ. សកម្មភាពដើម្បីកាត់បន្ថយ ការផ្លាស់ទីរបស់ការបំភាយឧស្ម័ន

# ការរៀបចំប្រព័ន្ធព័ត៌មានស្តីពីការធានាសុវត្ថិភាព (SIS)

- សេចក្តីសម្រេចរបស់ UNFCCC លើកឡើងថា រដ្ឋភាគីដែលជាប្រទេសកំពុងអភិវឌ្ឍ ត្រូវបង្កើតប្រព័ន្ធមួយ **ដើម្បីផ្តល់ព័ត៌មានអំពីរបៀបដែល ការធានាសុវត្ថិភាពរេដបូក ត្រូវបានធ្វើឡើង និងគោរព** នៅក្នុងការអនុវត្តសកម្មភាពរេដបូកទាំងមូល ។

- ដោយធ្វើការពិចារណាលើសេចក្តីសម្រេចទាំងនេះ ប្រទេសកម្ពុជាប្រើប្រាស់អភិក្រម ៣ ជំហាន ដើម្បីបង្កើតប្រព័ន្ធព័ត៌មានស្តីពីការធានាសុវត្ថិភាពរបស់ខ្លួន ដូចជា **១. ការបង្កើតសូចនាករ ផ្អែកទៅតាមសូចនាករ ដែលត្រូវបានប្រើប្រាស់ នៅក្នុងគោលនយោបាយ និងវិធានការដែលមានស្រាប់** ២. ការជ្រើសរើសវិធីសាស្រ្តសម្រាប់ប្រមូល និងវិភាគទិន្នន័យ និង ៣. ការកំណត់ពីការទទួលខុសត្រូវរបស់ស្ថាប័ន ក្នុងការផ្តល់ព័ត៌មាន។

# ជំពូកទី ៦ ៖
# ការគ្រប់គ្រងហិរញ្ញវត្ថុនៃយុទ្ធសាស្ត្រជាតិស្តីពីរេដបូក

## ៦.១. មូលនិធិរេដបូកដែលស្នើឡើងនៅកម្ពុជា

- បើទោះបីជាមានភាពជឿនលឿនខាងផ្នែកការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងរយៈពេល ប៉ុន្មានឆ្នាំចុងក្រោយនេះក៏ដោយ ឧបសគ្គផ្នែកសមត្ថភាពនៅតែមាន ហើយដែលគួបផ្សំជាមួយនឹងភាពស្មុគស្មាញនៃរេដបូក និងទស្សនទាននៃការទូទាត់ផ្អែកតាមលទ្ធផលជាក់ស្តែងផង ការបំពេញការងារអាចមិនបានដល់កម្រិតល្អបំផុត ប្រសិនបើការទូទាត់រេដបូកត្រូវបានគ្រប់គ្រង ដោយប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសតែមួយគត់។

- លើសពីនេះ បទពិសោធន៍បង្ហាញថា ពុំមានប្រទេសអនុវត្តរេដបូកណាមួយ កន្លងមក ជ្រើសរើសយកការគាំទ្រថវិកាធ្វើជាទម្រង់ការ សម្រាប់ទូទាត់រេដបូកនោះឡើយ ប៉ុន្តែប្រទេសទាំងនោះអាចបង្កើតមូលនិធិរេដបូកដោយឯករាជ្យ ឬដាក់បញ្ចូលរេដបូក ទៅក្នុងមូលនិធិព្រៃឈើ ឬមូលនិធិប្រែប្រួលអាកាសធាតុដែលមានស្រាប់បាន។

- ការសិក្សា ដែលធ្វើឡើងដោយលេខាធិការដ្ឋានក្រុមការងាររបស់ប្រទេសកម្ពុជា បានផ្តល់ជាអនុសាសន៍ឲ្យមានការប្រើប្រាស់អភិក្រមមូលនិធិមួយ ដើម្បីគ្រប់គ្រងការទូទាត់រេដបូក នៅក្នុងដំណាក់កាលអន្តរកាលដំបូង ហើយដំណាក់កាលទីពីរបន្ទាប់ អាចប្រើប្រាស់ប្រព័ន្ធរបស់ប្រទេសកាន់តែច្រើនជាងមុន បន្ទាប់ពីមានអន្តរកាលរួចមក

# ការរៀបចំមូលនិធិ ដេបូកដែលបានស្នើឡើង



# ការប្រើប្រាស់ការទូទាត់រេដបូកផ្អែកតាមលទ្ធផលដែលបានស្នើឡើង




CONFIDENTIAL

# ជំពូកទី ៧ ៖ ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ (NFMS)

- ដើម្បីឱ្យរដ្ឋភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍ ទទួលបានហិរញ្ញប្បទានផ្អែកតាមលទ្ធផល សកម្មភាពរេដបូកគួរត្រូវបាន**វាស់វែង រាយការណ៍ និងផ្ទៀងផ្ទាត់**ឱ្យបានពេញលេញ- ការសម្រេចរបស់ COP

- ទិន្នន័យ និងព័ត៌មាន ដែលត្រូវបានប្រើប្រាស់ ដោយភាគី ដើម្បីធ្វើការប៉ាន់ប្រមាណពីការបំភាយឧស្ម័ន ពីព្រៃឈើ ដោយសារសកម្មភាពមនុស្ស **ដោយបែងចែកតាមប្រភព និងការដកចេញដោយសារការស្រូបកាបូន ស្តុកកាបូនព្រៃឈើ និងការផ្លាស់ប្តូរតំបន់ព្រៃ សមស្របតាមសកម្មភាពរេដបូក** ដែលធ្វើ**ឡើងដោយភាគី គួរមានតម្លាភាព សង្គតិភាព ជាមួយនឹងកម្រិតយោង នៃការបំភាយឧស្ម័នពីព្រៃឈើ (FRELs) និង/ឬកម្រិតយោងរបស់ព្រៃឈើ (FRLs) ដែលបានកំណត់**។

  UNFCCCC Conference of the Parties, Decision 14/CP.19. Par. 3

- រដ្ឋភាគី ដែលជាប្រទេសកំពុងអភិវឌ្ឍ ត្រូវបានលើកទឹកចិត្តឱ្យកំណត់ពី FRELs និង/ឬ FRLs ទៅតាមកាលៈទេសៈ និងសមត្ថភាពជាតិ ឬក្នុងករណីសមស្រប កំណត់ FRELs និង/ឬ FRLs នៅថ្នាក់ក្រោមជាតិ សម្រាប់ធ្វើជារង្វាស់អន្តរកាល UNFCCCC Conference of the Parties, Decision 1/CP.16. Par. 71

# ជំពូកទី ៧ ៖ ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ (NFMS)

ប្រព័ន្ធពិនិត្យតាមដានព្រៃឈើជាតិ មានសសរស្តម្ភចំនួន ៣៖

1. ប្រព័ន្ធពិនិត្យតាមដានដីធ្លីដោយប្រើប្រាស់ផ្កាយរណប (SLM)
2. ការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ (NFI)
3. សារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ (GHG)

# ១. ប្រព័ន្ធពិនិត្យតាមដានដីធ្លីដោយប្រើប្រាស់ផ្កាយរណប (SLM)

- យកផែនទីគម្របព្រៃឈើ២០១៣/២០១៤ ជាផែនទីគោលសម្រាប់វាយតម្លៃប្រវត្តិនៃការប្រែប្រួលគម្របដី- ដោយបែងចែកជា ២២ ចំណាត់ថ្នាក់
- *រដ្ឋបាលព្រៃឈើទទួលខុសត្រូវក្នុងការរៀបចំរៀបចំ និងការវិភាគលើផែនទីគម្របព្រៃឈើ*
- វិធីសាស្រ្តថ្មីត្រូវបានណែនាំក្នុងការវារៀបចំផែនទី 2005, 2010 និង 2014
- នឹងធ្វើបច្ចុប្បន្នភាពទិន្នន័យសកម្មភាពក្នុងចន្លោះ ២ឆ្នាំម្តង, រាយការនៅក្នុង របាយការជាតិ និង របាយការណ៍ពីឆ្នាំម្តងទៅ UNFCCC

## ២. ការធ្វើសារពើភ័ណ្ឌព្រៃឈើជាតិ (NFI)

- នឹងគាំទ្រដល់ការរៀបចំ និងផ្ដល់ព័ត៌មានថ្មីៗ ស្ដីពី កត្តាបំភាយសម្រាប់ប្រភេទនៃការប្រែប្រួលដីទាំងអស់
- នឹងរៀបចំ៥ឆ្នាំម្ដង, ជ្រើសរើស អាងស្ដុបការបូន (១) ជីវម៉ាសលើដី (២) ជីវម៉ាសក្រោមដី និង អាស្ដុបកាបូនផ្សេងទៀត ដូចជា ដី និង កំទេសកំទី វិភាគបន្ទាប់ទៀត
- *នឹងផ្ដល់ព័តមានសម្រាប់ ការអនុវត្តគោលនយោបាយនិងវិធានរបស់រេដ និង ប្រព័ន្ធព័តមានជានាសុវត្ថិភាពរេដបូក (SIS)*
- គម្រោងសំណើការរៀបចំសារពើព្រៃឈើជាតិនឹងបញ្ចប់ចុងឆ្នាំ២០១៥
- រដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ និងក្រ. បរិស្ថាន ទទួលខុសត្រូវក្នុងការរៀបចំសារពើភ័ណ្ឌព្រៃឈើក្នុងដែនរបស់ខ្លួន។

## ៣. សរពើភណ្ឌឧស្ម័នផ្ទះកញ្ចក់

- *ប្រទេសកម្ពុជានឹងប្រើ IPCCC 2006 ដើម្បីធានាថាមានភាពស៊ីគ្នាក្នុងចំនោំណោមការរាយការណ៍ឧស្ម័នផ្ទះកញ្ចក់*

- ឧស្ម័នកាបូននិច នឹងជ្រើសរើសសម្រាប់រាយការ

- សម្រាប់ការធ្វើសារពើភណ្ឌ តែនឹងប្រើ *stock different approach នឹងប្រើនៅពេលទិន្នន័យគ្រប់គ្រាន់*

- កំណត់យកកម្រិត Tier១ ប្រទេសកម្ពុជានឹងចាប់ផ្តើមពីកម្រិត Tier 2 និងបន្ថែមការគាំទ្រពី Tire ១ នៅពេល Tire ២ មិនទាន់មាន

# ភាពស៊ីគ្នា, អាចជឿជាក់បាន និងតម្លាភាព

- *ប្រព័ន្ធត្រួតពិនិត្យព្រៃឈើជាតិកម្ពុជានឹងបង្កើតឡើងបានតម្រូវការប្រមូលទិន្នន័យពី ប្រព័ន្ធព័តមានទាំងប្រពភ*

- *ទិន្នន័យនឹងត្រូវបង្ហាញនៅលើ គេហទំព័រ ដើម្បីអោយមានតម្លាភាព និងអាចមើលឃើញ ពីលទ្ធផលនៃការអនុវត្តរេដបូក*

# ជំពូកទី ៨ ៖ ការរៀបចំកម្រិតបំភាយយោង

- នឹងរៀបចំថ្នាក់ជាតិ

- Tier 2 នឹងប្រើប្រាស់សម្រាប់រៀបចំ Tier 2  និង Tire 3 នឹងប្រើប្រាស់នាពេលអនាគត។

- ***ការបាត់បង់ព្រៃឈើ ៖*** នឹងដោះស្រាយជាដំបូងគេ ដោយមានការគាំទ្រគណនាកម្រិតបំភាយចេញពី ការបាត់បង់ព្រៃឈើ ដោយ FREL/REL។  ចំពោះការថយរេចរឹលព្រៃឈើ នឹងធ្វើការវាយតម្លៃនាពេលអនាគត បន្ទាប់ពីការធ្វើការពើភណ្ឌថ្នាក់ជាតិចំនួន ២ ដងរួច។

- នឹងការវិភាគ ***ការរេចរឹលនៃព្រៃឈើ*** *នឹងប្រើរូបភាពផ្កាយរណបដែលមាន Resolution ធំ និងបន្ថែមដោយការវាយតម្លៃនៅទីវាលផងដែរ។*

- FREL លើទី១ នឹងរៀបចំ។ ប្រទេសកម្ពុជានឹងជ្រើសរើស $CO_2$ ដើម្បីរាយការណ៍ និងគណនា នៅពេលដែលប្រទេសមានសម្ថភាព និងបច្ចេកទេគ្រប់គ្រាន់  មានធនធានគ្រប់គ្រាន់ និងបទពិសោធន៍ នោះនឹងជ្រើសរើសយកឧស្ម័នផ្សេងទៀតមកគណនា និងរាយការណ៍។

- ការវាយតម្លៃ FREL/REL។ ប្រទេសកម្ពុជា ជ្រើសរើសអាងស្តុបកាបូនសម្រាប់គណនា FREL/REL ដូចជា ***ជីវម៉ាសលើដី និង ជីវម៉ាសក្រោមដី***

- រយៈពេលនៃកម្រិតបំភាយយោល គឺ ២០០៥-២០១៤។ ការប្រើប្រាស់គម្របព្រៃ ឆ្នាំ២០១៤ ជាផែនទីគោល។

- ចំពោះនិយមន័ព្រៃឈើ ដែលនឹងប្រើប្រាស់នៅក្នុងយន្តការរេដបូក គឺ៖

"*trees higher than 5 meters on an area of at least 0.5 hectare with a canopy of more than 10 per cent*". Plantations such as rubber, palm oil, teak, acacia, and eucalyptus and fruit trees such as mango, cashew orchards are not classified as forest" ?

# ជំពូកទី ៩៖ ការរៀបចំស្ថាប័នសម្រាប់ការអនុវត្តយុទ្ធសាស្ត្រ

- ការរៀបចំស្ថាប័ន សម្រាប់អនុវត្តយុទ្ធសាស្ត្រជាតិស្តីពីរេដបូកនៅកម្ពុជា ចាំបាច់ត្រូវទទួលស្គាល់ពី តួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធររដ្ឋាភិបាល ដែលមានសមត្ថកិច្ចយុត្តាធិការលើធនធានព្រៃឈើ នៅក្នុងប្រទេសនេះ។

- ដូច្នេះ ការអនុវត្តរេដបូកត្រូវអនុវត្តតាមយុត្តាធិការនៃស្ថាប័នរបស់រដ្ឋាភិបាល ដោយស្ថាប័នផ្សេងៗរបស់រដ្ឋាភិបាលត្រូវរៀបចំយុទ្ធសាស្ត្រអនុវត្តរេដបូក សម្រាប់តំបន់ព្រៃផ្សេងៗគ្នាផ្អែកទៅតាមច្បាប់ និងគោលនយោបាយ ដែលមានស្រាប់របស់រាជរដ្ឋាភិបាលកម្ពុជា។

- ការអនុវត្តនេះត្រូវមាន មូលដ្ឋានលើក្របខ័ណ្ឌជាតិ ដោយហេតុថារេដបូកតម្រូវឱ្យមានការអនុវត្តនៅថ្នាក់ជាតិ និងការរៀបចំ របាយការណ៍ថ្នាក់ជាតិ ដើម្បីដាក់ជូន UNFCCC។

## ៩.១. ការសម្របសម្រួលនៅថ្នាក់ជាតិ

### ស្ថាប័នសំខាន់ៗ៖

- គណៈកម្មាធិការជាតិប្រែប្រួលអាកាសធាតុ (NCCC)
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)
- ក្រសួង បរិស្ថាន (MoE)
- ក្រុមការងាររេដបូកកម្ពុជា (Taskforce)
- ក្រុមការងារបច្ចេកទេសរេដបូកចំនួន ៤ (Technical Teams)
- ក្រុមពិគ្រោះយោបល់រេដបូក (Consultation Group)
- ក្រុមយេនឌ័ររេដបូក (Gender Group)
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)
- ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ (MLMUPC)

# អរគុណ !